រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

048KH01A-01

ចូរយើងចេញទៅសួរសុខទុក្ខ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៨

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយអោយក្រុមជំនុំរបស់អ្នក ចេញទៅសួរសុខទុក្ខអស់អ្នក ដែលមានសេចក្តីត្រូវការ និង អ្នកដែលមិនទាន់ស្គាល់ព្រះគ្រីស្ត ។

យ៉ាកុប ១:២៧ ចែងថា÷ *«រីឯសាសនាដ៏បរិសុទ្ធឥតខ្ចោះ នៅចំពោះព្រះភ័ក្ត្រព្រះបិតាជាម្ចាស់វិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និង ស្ត្រីមេម៉ាយដែលមានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនឱ្យផុតពីអំពើសៅហ្មងរបស់លោកីយ៍នេះ»* ។

ការទៅសួរសុខទុក្ខមនុស្សឯទៀត ដើម្បីទៅផ្សាយដំណឹងល្អ និងលើកទឹកចិត្តពួកគេ ជាកិច្ចការបំរើសំខាន់បំផុតរបស់ក្រុមជំនុំទាំងអស់ ដែលដំណើរការល្អ ។ យើងច្រើនតែបញ្ឈប់សកម្មភាពកំសាន្ត ដើម្បីយកពេលទៅសួរសុខទុក្ខមនុស្សឯទៀត ។



កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

តើយើងត្រូវទៅសួរសុខទុក្ខអ្នកណាខ្លះ ?

យើងទៅសួរសុខទុក្ខអ្នកដែលមានសេចក្តីត្រូវការ

សូមអាន យ៉ាកុប ១:២៧ និង ៥:១៤ ។ ការរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនមែនត្រឹមតែចេះគោលជំនឿ និងរក្សាខ្លួនមិនប្រព្រឹត្តអាក្រក់ប៉ុណ្ណោះទេ គឺថែមទាំងត្រូវចេះបង្ហាញសេចក្តីស្រឡាញ់ ដោយសកម្មភាព ចំពោះមនុស្សគ្រប់រូបផងដែរ (យ៉ាកុប ១:២៧) ។ យើងត្រូវទៅសួរសុខទុក្ខពួកអ្នកដែលមានទុក្ខលំបាក ដូចជាកូនកំព្រា ស្ត្រីមេម៉ាយ អ្នកជំងឺ និង មនុស្សជាប់ឃុំឃាំង ។



យើងទៅសួរសុខទុក្ខអ្នកមិនទាន់ជឿលើព្រះយេស៊ូ

សូមអាន ម៉ាកុស ១៦:១៥ ។ មានមនុស្សខ្លះ កំព្រាខាងព្រលឹងវិញ្ញាណ (គឺអ្នកនោះមិនទាន់ស្គាល់ព្រះបិតា ដែលគង់នៅស្ថានបរមសុខទេ) ។ ការដែលយើងទៅសួរសុខទុក្ខពួកគេ ដើម្បីប្រកាសដំណឹងល្អប្រាប់ពួកគេ អាចនាំពួកគេឱ្យចូលជាសមាជិកគ្រួសាររបស់ព្រះជាម្ចាស់បាន ។ ការទៅសួរសុខទុក្ខ និង ការជជែកលេងជាមួយគ្នាដោយផ្ទាល់ ជារបៀបល្អបំផុតសំរាប់នាំមនុស្សអោយជឿលើព្រះយេស៊ូ ។



កំណត់ចំណាំ :

© Project WorldReach © SEAN

- អ្នកត្រូវរៀបចំ និង ចាត់ចែងក្រុមសួរសុខទុក្ខផ្សេងៗ ហើយអធិស្ឋានសំរាប់ក្រុមទាំងអស់នោះ រួមជាមួយអ្នកដឹកនាំឯទៀតរបស់ក្រុមជំនុំ ។

  ត្រូវចាត់តាំងអ្នកចាត់ចែង សំរាប់ក្រុមសួរសុខទុក្ខនិមួយៗ ហើយអ្នកអាចប្រើរបៀបកត់ត្រា តាមគំរូនៅខាងក្រោមនេះ :

តារាងបង្ហាញការទៅសួរសុខទុក្ខ

អ្នកចាត់ចែង : _____

អ្នកដែលទៅលេង :	គេត្រូវទៅលេងអ្នកណា :	កាលបរិច្ឆេទ :

យើងទៅសួរសុខទុក្ខអ្នកដែលបែកចេញពីព្រះជាម្ចាស់

សូមអាន យ៉ាកុប ៥:១៩-២០ ។ យើងកែតម្រង់អ្នកដែលធ្លាក់ចុះអោយវិលមករកព្រះជាម្ចាស់វិញ ។ អ្នកទាំងនោះ បានស្គាល់សេចក្តីពិតហើយ តែបែរចេញពីព្រះជាម្ចាស់ ដោយមូលហេតុអ្វីមួយ ។ យើងមិនត្រូវបោះបង់ចោលពួកគេទេ ។ នៅពេលដែលយើងទៅសួរសុខទុក្ខពួកគេ ដោយសេចក្តីស្រឡាញ់ អ្នកទាំងនោះអាចវិលមកជានានឹងព្រះជាម្ចាស់វិញ ។



យើងត្រូវទៅលេងអ្នកជឿថ្មី

សូមអាន ម៉ាថាយ ២៨:១៩-២០ ។ ពួកអ្នកជឿថ្មីត្រូវការជំរុញទ្រានិង ការលើកទឹកចិត្ត ។ មហាបណ្តាំរបស់ព្រះគ្រីស្ត នៅក្នុងខទាំងនេះ បង្គាប់យើងឱ្យបង្រៀនពួកអ្នកជឿថ្មី ឱ្យក្លាយជាសាវ័ក ដោយជាស់តឿនអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ។ របៀបដែលល្អបំផុត ក្នុងការបំពេញតាមមហាបណ្តាំនេះ គឺទៅសួរសុខទុក្ខពួកអ្នកជឿថ្មី ។



គ- ផ្សាយដំណឹងល្អប្រាប់បណ្តាជន និង បង្រៀនអ្នកជឿថ្មី អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ ដូចតទៅ :

- កែប្រែចិត្តគំនិត និង ជឿ
- ទទួលពិធីជ្រមុជទឹក
- មានសេចក្តីស្រឡាញ់ និង ជួយមនុស្សឯទៀតដោយ សកម្មភាព ឬ ការប្រព្រឹត្ត (ស្របទៅតាមអំណោយទានរបស់ពួកគេ)
- ចូលរួមធ្វើពិធីកាច់នំប៉័ង
- អធិស្ឋានម្នាក់ឯង និង រួមជាមួយក្រុមគ្រួសារ
- ជាក់ជង្វាយ (ធ្វើអំណោយ) ដោយចិត្តសប្បុរស
- នាំក្រុមគ្រួសាររបស់ខ្លួនអោយជឿលើព្រះគ្រីស្ត ។ ពួកគេអាចប្រើមេរៀន « ដំណឹងល្អបំផុត » និង « ការប្រតិបត្តិតាមព្រះអម្ចាស់យេស៊ូគ្រីស្ត » (កិរិតទី ១) ។

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀន និង រៀបចំក្រុមជំនុំរបស់អ្នកអោយចេះទទួលខុសត្រូវចំពោះ :

  ក- ការទៅសួរសុខទុក្ខ និង ការជួយអ្នកដែលមានសេចក្តីត្រូវការ ។

  ខ- ការទៅអធិស្ឋានសំរាប់អ្នកដែលវង្វេងចេញពីព្រះ-ជាម្ចាស់ និង អធិស្ឋានជាមួយពួកគេ ហើយផ្តល់ដំបូន្មានដល់ពួកគេ ដោយប្រើខព្រះគម្ពីរ ។

យើងនឹងទៅសួរសុខទុក្ខអ្នកជឿដែលស្មោះត្រង់

សូមអាន កិច្ចការ ២:៤២ ។

ក្រុមជំនុំដំបូងនៅក្រុងយេរូសាឡឹម ព្យាយាមធ្វើសកម្មភាពបួនយ៉ាង :

១- ស្តាប់សេចក្តីបង្រៀន (គោលជំនឿ)

២- អធិស្ឋាន

៣- ធ្វើពិធីកាច់នំប៉័ង

៤- រួមរស់ជាមួយគ្នាជាបងប្អូន ។

យើងអាចរួមរស់ជាមួយគ្នាបាន ដោយទៅចូលរួមថ្វាយបង្គំជាមួយគ្នា និង ទៅសួរសុខទុក្ខគ្នាទៅវិញទៅមក ដើម្បីជួយគ្នាធ្វើកិច្ចការផ្សេងៗ ។ យើងទៅសួរសុខទុក្ខអ្នកជឿចាស់ទុំ ដែលស្មោះត្រង់ ។ ធ្វើដូចនេះ យើងជួយលើកទឹកចិត្តគ្នាទៅវិញទៅមក ។



បង្រៀនអ្នកជឿថ្មីដោយធ្វើជាគំរូ អោយពួកគេធ្វើតាម ។

ដំបូន្មានស្រួលអនុវត្ត ដើម្បីអោយ ការសួរសុខទុក្ខមានប្រសិទ្ធិភាព

- សព្វថ្ងៃនេះ គ្រួសារជាច្រើនមិនទទួលអ្នកទៅសួរសុខទុក្ខ តាមផ្ទះពួកគេ ដោយសារមានពួកម៉ារ៉ុន និង ពួកសួរ-បន្ទាល់ព្រះយេហូវ៉ា ទៅសួរសុខទុក្ខតាមផ្ទះ ។ ហេតុនេះ យើងសូមជូនយោបល់ដល់អ្នកថា ជំបូង អ្នកគួរតែទៅសួរសុខទុក្ខមនុស្សដែលអ្នកធ្លាប់ស្គាល់សិន ដូចជា អ្នកជិតខាង មិត្តភក្តិ សាច់ញាតិ អ្នកធ្វើការជាមួយជាដើម ។ មនុស្សដែលស្គាល់អ្នក ច្បាស់ជាស្វាគមន៍ទទួលអ្នក ហើយស្តាប់អ្នក ។ លើសពីនេះទៅទៀត មនុស្សដែលអ្នកចាប់ផ្តើមស្គាល់ អាចនាំអោយអ្នកបានស្គាល់មនុស្សឯទៀត ។ អ្នកអាចទាក់ទងស្គាល់មនុស្សកាន់តែច្រើនឡើងៗ តាមរបៀបនេះ ។ បានសេចក្តីថា ការស្គាល់មនុស្សម្នាក់ នឹងនាំអោយស្គាល់មនុស្សផ្សេងទៀតជាបន្តបន្ទាប់ ។



ពួកអ្នកដែលបែរចេញពីព្រះជាម្ចាស់
ត្រូវការសេចក្តីស្រឡាញ់រាប់អានពីយើងណាស់ ។
យើងត្រូវនាំគ្នាទៅសួរសុខទុក្ខពួកគេ ដោយអំណត់ ។

© Project WorldReach © SEAN

- ដើម្បីអោយការទៅសួរសុខទុក្ខកាន់តែមានប្រសិទ្ធិភាព អ្នកត្រូវរៀបចំផែនការ និង ចាត់ចែងការទៅសួរសុខទុក្ខ ដោយអធិស្ឋានអោយបានច្រើន ។ សមាជិកដែលទៅសួរសុខទុក្ខត្រូវធ្វើបញ្ជីកត់ឈ្មោះគ្រួសារ ឬ មនុស្សដែលពួកគេបានទៅសួរសុខទុក្ខហើយ ដើម្បីកុំអោយពួកគេទៅសួរសុខទុក្ខជាន់គ្នា ឬ ភ្លេចមិនបានទៅសួរសុខទុក្ខអ្នកឯទៀត ដែលត្រូវការជំនួយ និង ការលើកទឹកចិត្ត ។ សូមបន្តទៅសួរសុខទុក្ខពួកអ្នក ដែលចាប់អារម្មណ៍ចំពោះដំណឹងល្អ នៅពេលក្រោយទៀត ។

- បង្ហាត់បង្រៀនអ្នកដែលត្រូវទៅសួរសុខទុក្ខ ។ បង្រៀនពួកគេអោយចេះដឹងពីរបៀបសួរសុខទុក្ខខាងក្រោមនេះ :

  - របៀបចាប់ផ្តើមការសន្ទនា និង របៀបនាំជជែកបន្តិចម្តងៗឆ្លងពីសេចក្តីខាងសាច់ឈាម ទៅដល់សេចក្តីខាងព្រលឹងវិញ្ញាណ ។
  - របៀបចែកចាយ/ ធ្វើទីបន្ទាល់ដែលមានប្រសិទ្ធិភាព ។
  - របៀបដឹកនាំមនុស្សអោយជឿលើព្រះគ្រីស្ត ។
  - របៀបអធិស្ឋានសំរាប់អ្នកជំងឺ ។

៣- យើងត្រូវទៅលេងអ្នកជឿថ្មី ដើម្បីបង្រៀនពួកគេអំពីព្រះ-យេស៊ូថែមទៀត ឯអ្នកចាស់ទុំជាសមាជិកស្មោះត្រង់ ក៏ត្រូវការឱ្យយើងទៅសួរសុខទុក្ខដែរ ។ យើងធ្វើដូចនេះ ដើម្បី :

- ☐ អធិប្បាយអោយពួកគេស្តាប់ ។
- ☐ ធ្វើឱ្យមានទំនាក់ទំនងជិតស្និទ្ធពិតរវាងគ្នា និង គ្នា ។

៤- យើងធ្វើអោយមានការរួបរួមគ្នា តាមរយៈការចេញទៅសួរសុខទុក្ខ ។ គ្រីស្តជនដែលវង្វេងចេញពីព្រះអង្គ ត្រូវការឱ្យយើង :

- ☐ បោះបង់ពួកគេឱ្យនៅក្នុងអំពើបាបរបស់ពួកគេ ។
- ☐ ទៅសួរសុខទុក្ខពួកគេ ដោយសេចក្តីស្រឡាញ់ ។
- ☐ បន្ទោសពួកគេ ពេលយើងជួបពួកគេ ។

- បើសិនជាយើងទៅសួរសុខទុក្ខអ្នកណាម្នាក់ យើងគួរទៅពីរៗនាក់ ទើបមានប្រយោជន៍ ។ ព្រោះព្រះយេស៊ូបានចាត់សាវ័ករបស់ព្រះអង្គអោយចេញទៅពីរៗនាក់ដែរ ។ បើទៅសួរសុខទុក្ខពីរៗនាក់ នោះអាចជួយគ្នាទៅវិញទៅមក គឺម្នាក់អាចអធិស្ឋាន ម្នាក់ទៀតអាចនិយាយ ។

- ជាទូទៅ គួរតែអោយបុរសទៅសួរសុខទុក្ខបុរស ស្ត្រីទៅសួរសុខទុក្ខស្ត្រី យុវជនទៅសួរសុខទុក្ខយុវជន ហើយអ្នកមានគ្រួសារ ទៅសួរសុខទុក្ខអ្នកមានគ្រួសារ បើសិនជាអាចធ្វើបាន ។

- ត្រូវទៅសួរសុខទុក្ខ នៅពេលដែលសមគួរសំរាប់ម្ចាស់ផ្ទះ ហើយបើអាចធ្វើបាន ត្រូវកំណត់ពេលម៉ោងទៅសួរសុខទុក្ខជាមួយគេជាមុន ។ ឧទាហរណ៍ ត្រូវចៀសវាងពេលបាយ ឬ ពេលវេលា ដែលពួកគេជាប់រវល់ធ្វើអ្វីផ្សេង ។

ការប្រឡង (សំឆ្លើយសង្ខេបមេរៀន)

១- សាវ័កយ៉ាកុបប្រាប់យើងអោយរក្សាខ្លួន កុំធ្វើតាមលោកីយ៍ និង :

☐ កុំអោយនិយាយជាមួយអ្នកមិនទាន់ជឿ ។

☐ អោយទៅសួរសុខទុក្ខអ្នក ដែលមានសេចក្តីត្រូវការ ។

២- ដើម្បីធ្វើអោយបានសំរេចតាមមហាបណ្តាំ ដែលនៅក្នុងម៉ាថាយ ២៨:១៩-២០ យើងត្រូវនាំពួកអ្នកមិនទាន់ជឿអោយថ្វាយខ្លួនទៅព្រះគ្រីស្ត ។ បន្ទាប់មក យើងបង្រៀនពួកគេអោយក្លាយជាសាវ័ក ដោយ :

☐ បង្រៀនពួកគេអោយប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ។

☐ ស្តីបន្ទោសពួកគេ នៅពេលដែលពួកគេខ្សោយខាងជំនឿ ។

- ត្រូវឆាប់យល់ចិត្តម្ចាស់ផ្ទះ កុំនៅយូរពេក នាំអោយគេធុញទ្រាន់ ។ បើអ្នកយល់ចិត្តគេដូចនេះ គេនឹងស្វាគមន៍អ្នកពេលអ្នកទៅសួរសុខទុក្ខគេលើកក្រោយទៀត ។



- បើអាចធ្វើបាន សូមទុកខិត្តប័ណ្ណ ឬ កូនសៀវភៅស្តីអំពីដំណឹងល្អអោយមនុស្ស ដែលអ្នកបានទៅផ្សាយដំណឹងល្អអាចអាននៅពេលក្រោយ ហើយត្រូវទុកអាស័យដ្ឋានអោយពួកគេដែរ ដើម្បីអោយពួកគេអាចទាក់ទងអ្នកបាន ។

- ត្រូវឧស្សាហ៍ទៅសួរសុខទុក្ខ ។ សូមកុំបោះបង់លែងទៅសួរសុខទុក្ខពួកអ្នក ដែលអ្នកធ្លាប់បានទៅសួរសុខទុក្ខហើយ ឱ្យសោះ ។



- គោលដៅនៃការទៅសួរសុខទុក្ខ គឺកសាងទំនាក់ទំនងមិត្ត-ភាព និង ចែកចាយដំណឹងល្អ តាមរយៈការជជែកលេងធម្មតា ។ ជជែកគ្នា បានន័យថា និយាយគ្នាទៅវិញទៅមក ។ ហេតុនេះ អ្នកត្រូវចៀសវាងកុំនិយាយតែម្នាក់ឯងរហូត និង កុំនិយាយពន្យល់ ឬ អធិប្បាយវែងៗអោយសោះ ។ មិនត្រូវប្រើពាក្យសាសនាជ្រៅៗពេកទេ ។ បើយកព្រះគម្ពីរធំពេកទៅជាមួយ អាចនាំឱ្យមនុស្ស ដែលអ្នកទៅសួរសុខទុក្ខលែងចាប់អារម្មណ៍ ។ ត្រូវខិតខំនិយាយពីអ្វីៗ ដែលអ្នកស្តាប់ចាប់អារម្មណ៍ ។



- អ្នកទៅសួរសុខទុក្ខត្រូវមានអនាម័យផ្ទាល់ខ្លួនល្អ និង ស្លៀកពាក់ស្អាតបាត ។ ប៉ុន្តែ កុំខិតខំស្លៀកពាក់ថ្លៃហ៊ីហា ឬពាក់គ្រឿងអលង្ការថ្លៃៗ ដែលនាំអោយម្ចាស់ផ្ទះគិតថា ពួកគេក្រខ្សត់ ឬ នាំអោយគេមានការតូចចិត្តនោះឡើយ ។



- បើសិនជាម្ចាស់ផ្ទះមិនស្វាគមន៍អ្នកទេ សូមកុំធ្វើអោយគេឃើញថា អ្នកមួម៉ៅ តែសូមចេញពីផ្ទះគេ ដោយគួរសម ។ ព្រះយេស៊ូបានទូន្មានថា មិនត្រូវបង្ហាតពេលនៅទីនោះទេ ។